# សំណួរត្រៀមពន្ធដារ

# សំណួរពន្ធដារ (ត្រៀមប្រឡង)

## ១.តើរដ្ឋមានមធ្យោបាយអ្វីខ្លះដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិកា?

ចំ.មានមធ្យោបាយជាច្រើនដើម្បីផ្តល់ហិរញ្ញប្បទានឱនភាពថវិកា។ ប្រទេសមួយអាចខ្ចីប្រាក់ពីបរទេស (កម្ចីពីបរទេស)ឬក៏អាចអនុវត្តន៍យកវិធានការមួយចំនួនដូចខាងក្រោមៈ

- បង្កើនចំនូលពន្ធៈ ប្រទេសមួយអាចបង្កើនចំនូលពន្ធដោយបង្កើនអត្រាពន្ធ ឬដាក់ចេញនូវបណ្តាប្រភេទពន្ធថ្មីៗ និងពង្រឹងសមត្ថភាពប្រមូលពន្ធ។ ចំណូលពន្ធដែលកើតឡើងអាចជួយកាត់បន្ថយ ឬលុបបំបាត់ឱនភាពថវិកា និងពង្រីកមូលដ្ឋានយកពន្ធ។

- ខ្ចីពីសាធារណៈជនដោយរួមមាន គ្រួសារ សាជីវកម្ម ក្រុមហ៊ុនធានារ៉ាប់រង និងស្ថាប័នហិរញ្ញវត្ថុដទៃទៀត។ នៅពេលដែលរដ្ឋាភិបាលចេញផ្សាយមូលបត្រ ដែលមួយផ្នែកនៃមូលបត្រទាំងនោះត្រូវកាន់កាប់ដោយសាធារណៈជនទូទៅ។ ហេតុនេះសាធា-រណៈជនទូទៅឱ្យរដ្ឋាភិបាលខ្ចីប្រាក់ ដោយការផ្ទេរមូលនិធិសន្សំទៅរដ្ឋាភិបាល។

-ខ្ចីប្រាក់ពីធនាគារកណ្តាល និងធនាគារពាណិជ្ជៈ ផ្នែកដ៏ធំនៃមូលបត្ររដ្ឋាភិបាលដែលនៅក្នុងនោះរួមមានប័ណ្ណរតនាគារ ត្រូវបានកាន់កាប់ដោយធនាគារកណ្តាល និងធនាគារពាណិជ្ជ។ ជាការពិតមូលបត្ររដ្ឋាភិបាលបង្កើតបានជាសមាសភាពដ៏ធំនៃទ្រព្យសកម្មរបស់ធនាគារកណ្តាល និងធនាគារពាណិជ្ជ រដ្ឋាភិបាលនឹងមានមធ្យោបាយជាច្រើនទៀតដើម្បីខ្ចីប្រាក់ពីធនាគារ។

- បោះពុម្ពលុយថ្មីបន្ថែមៈ ប្រការនេះនឹងបង្កើនការផ្គត់ផ្គង់លុយ។ វិធីចុងក្រោយនេះមិនគួរត្រូវបានយកមកប្រើឡើយ លុះណាតែមានមធ្យោបាយផ្សេងពីនេះ ក្នុងការផ្តល់ហិរញ្ញប្បទានឱនភាពថវិការដ្ឋ។

## ២.តើពន្ធមានឥទ្ធិពលអ្វីខ្លះដល់ផលិតផលក្នុងស្រុកសរុប?

ផលិតផលក្នុងស្រុកសរុប = ការប្រើប្រាស់+ការវិនិយោគ+ការចំណាយរដ្ឋាភិបាល+ការនាំចេញសុទ្ធ

ចំ. ពន្ធមានឥទ្ធិពលដល់ផលិតផលក្នុងស្រុកសរុបដូចជាៈ

- ប៉ះពាល់មកលើការប្រើប្រាស់ៈ ពន្ធលើចំណូលបុគ្គល ពន្ធលើទំនិញប្រើប្រាស់
- ប៉ះពាល់មកលើការវិនិយោគៈ ពន្ធលើប្រាក់ចំណេញ ពន្ធលើទំនិញដែលប៉ះពាល់លើបរិមាណទំនិញ ដែលត្រូវលក់។
- ប៉ះពាល់ការចំណាយរដ្ឋាភិបាលៈ អាចឱ្យរដ្ឋាភិបាលចាយថែម
- ប៉ះពាល់ការនាំចេញសុទ្ធៈ ការបង់ពន្ធគយនាំចេញ-នាំចូល។

## ៣.តើរដ្ឋធ្វើដូចម្តេចដើម្បីពង្រឹងការគ្រប់គ្រងគោលនយោបាយសារពើពន្ធ?

ចំៈ ការពង្រឹងការគ្រប់គ្រងសារពើពន្ធឱ្យបានសុក្រឹត គឺសំដៅលើការកែលម្អប្រព័ន្ធពន្ធដារដែលរួមបញ្ចូលទាំងពន្ធក្នុងប្រទេសទាំងពន្ធអាករនៃពាណិជ្ជកម្មអន្តរជាតិ ការកែលម្អរដ្ឋបាល ពន្ធដារ និងការប្រមូលពន្ធការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធរតនាគារ និងពង្រឹងវិន័យសារពើពន្ធ។ ជាមួយគ្នានេះរដ្ឋផ្តល់ការយកចិត្តទុកដាក់ទៅលើការកែលម្អកិច្ចអាទិភាវូបនីយកម្មសាធារណៈការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង វិនិយោគផ្ទាល់ពីបរទេស និងក្នុងការគ្រប់គ្រងប្រព័ន្ធលើក ទឹកចិត្តសំរាប់ការវិនិយោគ និងការពង្រឹងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ។

កិច្ចការនេះរួមបញ្ចូលទាំងការអនុវត្តយ៉ាងម៉ត់ចត់នូវច្បាប់ស្តីពីសារពើពន្ធ ការប្រឆាំងនឹងអំពើពុករលួយ និងការគេចវេសពន្ធការលុបបំបាត់ការលើកលែងពន្ធ ដែលមិនមានកំណត់នៅក្នុងច្បាប់ដែលមិនមានកំណត់នៅក្នុងច្បាប់ ការគ្រប់គ្រងដ៏ត្រឹមត្រូវនូវ

ទ្រព្យសម្បត្តិ និងធានាការគ្រប់គ្រង និងការធ្វើ អាជីវកម្មប្រកបដោយចីរភាពលើធនធានធម្មជាតិ។ រាល់ប្រតិបត្តិការថវិកាទាំងផ្នែកចំណូល និងចំណាយ ត្រូវតែធ្វើឡើងឱ្យស្របទៅនឹងវិធាន និងនីតិវិធីជាផ្លូវការ។ ចំពោះចំណាយត្រូវចាយឱ្យចំមុខសញ្ញាអាទិភាពនៃការអភិវឌ្ឍ។ ដាច់ខាតមិនត្រូវចាយឱ្យលើសពីធនធានដែលរកបានដើម្បីជៀសវាងការធ្វើហិរញ្ញប្បទានឱនភាពថវិកាតាមរយៈការយកលុយពីធនាគារជាតិ។

## ៤. តើគោលនយោបាយពន្ធមានមានគោលបំណងអ្វីខ្លះ?

ចំ. ក្នុងប្រទេសកំពុងអភិវឌ្ឍន៏ក៏ដូចជាប្រទេសដទៃទៀត គោលបំណងពន្ធក៏ដើម្បីប្រមូលថវិកាសម្រាប់ទ្រទ្រង់ស្ថាប័នរដ្ឋ ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាសាធារណៈចំពោះសង្គមគោលបំណងផ្សេងទៀត គឺជំរុញការបែងចែកឡើងវិញនូវរាល់ចំណូល និងកំណែតម្រូវអសុក្រឹត្យភាពទីផ្សារ។ ដើម្បីសម្រេចគោលបំណងទាំងនេះ ទោះជាការយកពន្ធក្នុងកម្រិតណាក៏ដោយសកម្មភាពនេះតែងតែមានបរិយាទាន ដែលរួមមានចំណាយផ្ទាល់លើកិច្ចការរដ្ឋបាលប្រមូលពន្ធ និងចំណាយដោយប្រយោលជាមួយនឹងការបែងចែកខុសនៃប្រភពធនធាន ព្រមទាំងផលវិបាកពីការបែងចែកចំណូល និងឥទ្ធិពលនៃការយកពន្ធទៅលើដំ-ណើរការអភិវឌ្ឍន៏សេដ្ឋកិច្ច។

## ៥. ដូចម្តេចដែលហៅថាពន្ធ?

ចំ. ពន្ធជាវិភាគទានមានលក្ខណៈកាតព្វកិច្ច(ចាប់បង្ខំ) ស្របតាមច្បាប់កំណត់ដែលអ្នកជាប់ពន្ធ ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ ការយកពន្ធជាមធ្យោបាយជាក់ស្តែងមួយដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនប្រាក់ចំណូល និងបំពេញការចំណាយរបស់រដ្ឋទៅលើទំនិញ និងសេវាដែលប្រជាជនភាគច្រើនត្រូវការ។ ទំនិញសាធារណៈដូចជាៈ ការការពារជាតិ និងកម្មវិធីធានារ៉ាប់រងសង្គមអាចត្រូវបានផ្តល់ជូនសង្គមជាតិវិញតាមរយៈការយកពន្ធដោយចាប់បង្ខំប៉ុណ្ណោះ។ ពិតណាស់ប្រសិនបើរដ្ឋអនុញ្ញាតឱ្យប្រជាជន(អ្នកជាប់ពន្ធ) បង់ពន្ធជូនរដ្ឋដោយស្ម័គ្រចិត្តនោះនឹងមានអ្នកជាប់ពន្ធមួយចំនួនតូចប៉ុណ្ណោះ ឬពុំមានអ្នកជាប់ពន្ធណាម្នាក់បង់ពន្ធជូនរដ្ឋឡើយ។ ដូច្នេះរដ្ឋនឹងទទួលចំណូលតិចតួចសម្រាប់បែងចែកជូនសង្គមជាតិវិញ និងប្រជាជនវិញតាមរយៈទំនិញ និងសេវាសាធារណៈរបស់រដ្ឋ។

ក៏ប៉ុន្តែបើសិនមានពន្ធចាប់បង្ខំដោយសមហេតុផល រដ្ឋអាចមានហិរញ្ញវត្ថុសម្រាប់ផ្គង់ផ្គង់សេចក្តីត្រូវការរបស់ប្រជាជន ហើយបង្កើតបាននូវទំនោរយល់ដឹងអំពីកាតព្វកិច្ចបង់ពន្ធរបស់ប្រជាជនផងដែរ ។ជាមួយនេះរដ្ឋត្រូវការហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ស្ថាប័នរបស់ខ្លួន។ តាមរយៈចំណូលពន្ធស្ថាប័នរបស់រដ្ឋអាច ដំណើរការបានក្នុងការបំពេញភារៈកិច្ច និងការដឹកនាំដើម្បីផ្តល់ទំនិញ និងសេវាសាធារណៈ។

## ៦. តើរដ្ឋមានប្រភពចំណូលពីណាខ្លះ?

ចំ.រដ្ឋមានប្រភពចំណូលពីបីប្រភពគឺៈ

១.ចំណូលសារពើពន្ធៈ រួមមានពន្ធលើផលទុន ប្រាក់ចំណេញ និងកម្រៃទុន(ពន្ធលើប្រាក់បៀវត្សន៏ ពន្ធលើប្រាក់ចំណេញ...) ពន្ធលើបិយតិកភ័ណ្ឌ(ពន្ធប្រថាប់ត្រា ពន្ធផ្ទេរមរតក) អាករលើផលរបរ អាករ លើតម្លៃបន្ថែមរួមទាំងរបបនាំចូល និងរបបផ្ទៃក្នុង ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស(ពន្ធគយពីការនាំចូល ពន្ធគយពីការនាំចេញ និងការផាកពិន័យរបស់គយ) និងចំណូលសារពើពន្ធផ្សេង១ទៀត(ការផាកពិន័យ និងទោសបញ្ញាត្តិសារពើពន្ធ)។

២.ចំណូលពុំមែនសារពើពន្ធៈរួមមានផលទុននៃទ្រព្យសម្បត្តិរដ្ឋ(ផលនេសាទផលព្រៃឈើ ផលទុនបានពីសហគ្រាសសាធារ-ណៈ ការជួលរោងចក្រ ការជួលសហគ្រាស ផលទុនរបបអាកាសករស៊ីវិល) និងចំណូលពុំមែនសារពើពន្ធផ្សេងទៀត (ផលទុនប្រៃសនីយ៍ និងទូរគមនាគមន៍ ផលទុនវិទ្យុ និងទូរទស្សន៍ ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ ព្រមទាំងចំណូលពីកូតានាំចេញ...) ។

៣.ចំណូលមូលធនរួមមានៈ ចំណូលផ្ទៃក្នុងជាមូលធន (ការលក់ទ្រព្យសម្បត្តិរដ្ឋ ដីធ្លី ផលទុនឯកជនភាវូបនិយកម្ម ចំនួលពីការខ្ចីក្នុងប្រទេស) ជំនួយពីបរទេស កម្ចីពីបរទេស អាករលើផលរបរ ចំនួលពីការលក់ប្រចាំឆ្នាំ ។

-កូតាៈការកំណត់បរិមាណទំនិញនាំចេញ-នាំចូល ។

## ៧. ដូចម្តេចហៅថារបបស្វ័យប្រកាស(របបពិត)?

ចំ. អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស គឺជានីតិបុគ្គល ទាំងឡាយដែលបានចុះ បញ្ជីរពាណិជ្ជកម្មនៅកម្ពុជា និងបុគ្គលទាំងឡាយដែលប្រកបធុរៈកិច្ចដែលមានផលរបរប្រចាំឆ្នាំ :

- ចាប់ពី ៥០០ លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់ទំនិញ
- ចាប់ពី២៥០លានរៀលឡើងទៅ សម្រាប់ការផ្គត់ផ្គង់សេវា
- ចាប់ពី១២៥លានរៀលឡើងទៅ សម្រាប់ការធ្វើកិច្ចសន្យាជាមួយរដ្ឋ ។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានកាតព្វកិច្ចដាក់ប្រកាស និងបង់ពន្ធដោយខ្លួនឯង ។ ក្នុងកំឡុងពេល
មួយមានកំណត់ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសនឹងត្រូវទទួលការធ្វើសនវកម្មពន្ធដារ ដើម្បីធានាភាពត្រឹមត្រូវនៃការប្រកាសរបស់ខ្លួន ។

នៅចុងឆ្នាំ២០០៨មានអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមានចំនួន១២០៨៩សហគ្រាស ក្នុងនោះមានសហគ្រាសអ្នកជាប់ពន្ធធំចំនួន១១៧១សហគ្រាសនៅទូទាំងប្រទេស និងអ្នកជាប់ពន្ធមធ្យមចំនួន៩១៤៤ សហគ្រាសនៅភ្នំពេញ១៧៧៤នៅតាមខេត្ត-ក្រុងទាំង២៤ ។ ចំណូលដែលទទួលបានពីអ្នកជាប់ពន្ធទាំងនេះ មានប្រមាណ៨៥%នៃចំណូលពន្ធដាសរុប ដែលអគ្គនាយកដ្ឋានពន្ធ-ដារប្រមូលបាន ។

## ៨.ដូចម្តេចដែលហៅថារបបម៉ៅការ?

ចំ. អ្នកជាប់ពន្ធតាមរបបម៉ៅការគឺជាអ្នកជាប់ពន្ធតូច ដែលស្ថិតនៅក្រោមកំរិតអប្បបរមាដែលត្រូវចុះបញ្ជី ជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវបានកំណត់ឱ្យបង់ប្រាក់ពន្ធក្នុងរយៈពេលកំណត់ណាមួយបីខែ ឬប្រាំមួយខែនៃឆ្នាំប្រតិទិន ។ នៅក្នុងរបបនេះមានសហគ្រាសតាមរបបម៉ៅការប្រមាណ១៥% នៃចំណូលពន្ធដែលអគ្គនាយកដ្ឋានពន្ធដារ រៀបចំមូលដ្ឋានត្រូវបង់ពន្ធស្របតាមបញ្ជីទាំងឡាយដែលប្រគល់មកដោយការប៉ាន់ប្រមាណជាក់ស្តែងណាស់ដែលថាប្រព័ន្ធនេះនឹងត្រូវចំណាយច្រើន ដើម្បីគ្រប់-គ្រងឱ្យបានប្រសើរឡើង ។

- របបសារពើពន្ធៈ

អ្នកជាប់ពន្ធទាំងឡាយត្រូវមានកាតព្វកិច្ចចុះបញ្ជីរនូវរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ថ្ងៃក្រោយមានសកម្មភាព
សេដ្ឋកិច្ច ។ ជាការអនុវត្តអ្នកជាប់ពន្ធនៅកម្ពុជាមានពីរប្រភេទគឺរបបស្វ័យប្រកាស និងរបបម៉ៅការ ចំពោះរបបបំព្រួញ គេមិនទាន់បានអនុវត្តទេ ។

## ៩.តើក្រសួងហិរញ្ញវត្ថុមានតួនាទីអ្វីខ្លះ?

ចំ. ក្រសួងហិរញ្ញវត្ថុដែលគ្រប់គ្រងកម្ចីប្រាក់ និងរក្សាទុនបម្រុងជារូបិយប័ណ្ណសរាប់ទប់ស្កាត់ឱនភាពថវិកា តាមរយៈការបង្កើន ចំនូលសារពើពន្ធ និងមិនមែនសារពើពន្ធ និងការកាត់បន្ថយចំណាយ ។

## ១០.ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ តើរដ្ឋាភិបាលពឹងផ្អែកលើចំណូលពន្ធអ្វីខ្លះ?

ចំ.ប្រទេសកំពុងអភិវឌ្ឍន៍ ពឹងផ្អែកយ៉ាងខ្លាំងលើពន្ធ លើប្រាក់ចំណូលរបស់ក្រុមហ៊ុនជាងពន្ធលើចំនូល របស់បុគ្គល។ ពន្ធលើចំណូលបុគ្គលជាទូទៅ ពិបាកប្រមូលនៅក្នុងប្រទេសដែលគ្របដណ្តប់ដោយសេដ្ឋកិច្ច ជនបទ ឬមានសេដ្ឋកិច្ចដែលសំបូរទៅដោយវិស័យក្រៅផ្លូវការច្រើន។

## ១១. តើកត្តអ្វីខ្លះដែលធ្វើឱ្យការគ្រប់គ្រងពន្ធខ្សោយ?

ចំ. កត្តាអវិជ្ជមានដែលធ្វើឱ្យការគ្រប់គ្រងពន្ធខ្សោយគឺ ភាពស្មុគស្មាញផ្នែកច្បាប់ និងបន្ទុកពន្ធ។ ប្រការ នេះជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះការធ្វើច្បាប់ និងនីតិវិធីពន្ធឱ្យកាន់តែងាយស្រួលអាច បង្កលក្ខណៈងាយស្រួល ដល់ការអនុវត្តច្បាប់ និងធ្វើឱ្យការគ្រប់គ្រងពន្ធកាន់តែមានប្រសិទ្ធភាព។

## ១២. ចូរនិយាយរៀបរាប់អំពីសភាពនៃការយកពន្ធនៅប្រទេសកំពុងអភិវឌ្ឍន៍?

ចំ. កត្តាប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ចជះឥទ្ធិពលលើសមាសភាពពន្ធនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងនោះ ពន្ធលើបុគ្គល ពិបាកប្រមូលនៅក្នុងសេដ្ឋកិច្ច ដែលគ្របដណ្តប់ដោយវិស័យកសិកម្ម និងដែលជាទូទៅប្រជា ជនរស់នៅបែកខ្ញែកគ្នា។ ជាលទ្ធផលមូលដ្ឋានពន្ធលើបុគ្គលច្រើនយកបានពីនិយោជិកសាធារណៈ និង និយោជិករបស់ក្រុមហ៊ុនធំៗ ជាពិសេសក្រុមហ៊ុនពហុជាតិ។ ជាទូទៅពន្ធលើផលចំណូលបុគ្គលតំណាងឱ្យ មួយភាគដប់នៃចំណូលពន្ធសរុប។ ដូច្នេះក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ចំណូលពន្ធច្រើនអាស្រ័យលើពន្ធ លើ ផលចំណូលក្រុមហ៊ុនច្រើនជាងពន្ធលើចំណូលបុគ្គល។ ពន្ធលើចំណូលរបស់ ក្រុមហ៊ុនតំណាងឱ្យប្រហែលមួយភាគបួននៃប្រាក់ចំណូលពន្ធសរុប។

ចំណូលពន្ធនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពឹងផ្អែកច្រើនលើពន្ធទំនិញ និងសេវា ជាពិសេសលើពន្ធ ពាណិជ្ជកម្មក្រៅប្រទេស។ ពន្ធលើទំនិញ និងសេវាមានចំនួនពាក់កណ្តាលគឺពីរភាគបីនៃចំណូលពន្ធសរុប ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយមួយភាគបួននៃចំណូលពន្ធបានមកពីពន្ធពាណិជ្ជកម្ម។

## ១៣.តើកំណែទម្រង់ពន្ធធ្វើឡើងដើម្បីអ្វី?

ចំ. កំណែទម្រង់ពន្ធធ្វើឡើងដើម្បី:

-ទីមួយៈ កំណែទម្រង់ពន្ធត្រូវបានបង្កើតឡើងសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយអសម- ភាពក្នុងការបែងចែកធនធាន។

-ទីពីរៈ កំណែទម្រង់ពន្ធត្រូវបានធ្វើឡើងដើម្បីទ្រទ្រង់ស្ថេរភាពសេដ្ឋកិច្ច និងសម្រាប់បង្កើនចំណូលសា ធារណៈ។

## ១៤.តើកត្តាអ្វីខ្លះ ដែលនាំឱ្យមានកំណែទម្រង់ពន្ធ?

ចំ. មូលហេតុដែលនាំឱ្យមានកំណែទម្រង់ពន្ធរួមមាន:

- ចំណូលមិនគ្រប់គ្រាន់

-ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនត្រូវញាំញីដោយឱនភាពសារពើពន្ធរ៉ាំរ៉ៃ និងដោយហេដ្ឋារចនា- សម្ព័នសេដ្ឋកិច្ច និងសង្គមមិនគ្រប់គ្រាន់។ ការបង្កើនចំណូលពន្ធផ្តល់ប្រាក់ចំណូលជាក់លាក់មួយសម្រាប់ ដោះស្រាយបញ្ហាទាំងនោះ។

- អស្ថេរភាពកំណើនសេដ្ឋកិច្ចៈ ការបង្កើនការយកពន្ធ ជារួមបង្កើតគុណវិបត្តិជាច្រើនក្នុងសេដ្ឋកិច្ច និង ឈានដល់កាត់បន្ថយជាក់ស្តែងរបស់សង្គមច្រើនជាងបរិមាណ និងកាត់បន្ថយចំណូលជាក់ស្តែងរបស់រដ្ឋ។ ការកាត់បន្ថយចំណូល-ចំណាយនេះចាត់ទុកជាបរិយាទាននៃប្រសិទ្ធភាពសេដ្ឋកិច្ចចំពោះការយកពន្ធ។

- អសមធម៌ក្នុងការបែងចែកធនធានសង្គមៈ ដោយសារអ្នកក្រីក្រទទួលបន្ទុកធ្ងន់ធ្ងរ ច្រើនជាងអ្នក ដែលមានជីវភាពប្រសើរជាង ដែលជាទូទៅបង់ពន្ធតិចតួចប៉ុណ្ណោះ ពីព្រោះចំណូលមួយថ្ងៃរបស់ពួកគេមិន មែនជាកំរៃឈ្នួល ឬជាប្រាក់បៀវត្សន៍ ច្រើនតែជាចំណូលបានមកពីការប្រកបការងារដោយខ្លួនឯង ឬ ចំណូលជាទំនិញមិនបានរាប់បញ្ចូលសម្រាប់យកពន្ធ ម្យ៉ាងទៀតដោយសារតែការកំណត់ ឬការគ្រប់គ្រង ខ្សោយរបស់រដ្ឋាភិបាលពន្ធ។ នៅប្រទេសកំពុងអភិវឌ្ឍន៍ ការយកពន្ធលើក្រុមអ្នកមានទ្រព្យសម្បត្តិច្រើន ឬមានអំណាច ជារួមពុំសូវមានប្រសិទ្ធភាពទេ ដោយសារការឃុបឃិតផ្សេងៗ ឬការពុំអនុវត្តច្បាប់។ ប្រការនេះនាំឱ្យមានវិវាទ រវាងអ្នកមាន និងអ្នកក្រកាន់តែឆ្ងាយឡើង ជាពិសេសនាំឱ្យមានអសមធម៌ក្នុង ការរស់នៅដែលទីបំផុត នឹងធ្វើឱ្យបញ្ហាសង្គម កើនទ្វេរឡើង បើសិនពុំមានកំណែទម្រង់នៃការបែងចែក នេះឱ្យបានច្បាស់លាស់ទេ។

- បញ្ហារដ្ឋបាលៈ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ការគ្រប់គ្រងពន្ធនៅខ្សោយ ហើយបញ្ហាគេច វេសពន្ធ និងអំពើពុករលួយជាទូទៅមានលក្ខណៈធ្ងន់ធ្ងរ។ ភាពទន់ខ្សោយក្នុងការគ្រប់គ្រងពន្ធ កើតចេញ មកពីកត្តាទំនាក់ទំនងទៅវិញទៅមកជាច្រើន រួមមានៈ ច្បាប់ និងនីតិវិធីពន្ធស្មុគស្មាញខ្លួនឯង ប្រព័ន្ធព័ត៌-មានខ្សោយ អំពើពុករលួយ និងឥទ្ធិពលនយោបាយក្នុងការគ្រប់គ្រងពន្ធ។ ការពង្រឹង និងពង្រីកការគ្រប់ គ្រងពន្ធដែលទាមទារឱ្យបង្កលក្ខណៈងាយស្រួលដល់ការកំណត់មូលដ្ឋានពន្ធគឺជាគោលដៅទីបួននៃកំណែ ទម្រង់ពន្ធ។

## ១៥.តើការគេចវេសពន្ធនាំឱ្យមានផលវិបាកអ្វីខ្លះ?

ចំ. ការគេចវេសពន្ធធ្វើឱ្យរេចរិលមូលដ្ឋានពន្ធ ព្រមទាំងប្រាក់ចំណូលសាធារណៈ។ ជាងនេះទៀតប្រភព ទុនដែលប្រើក្នុងការគេចពន្ធដែលមិនរួចចំណែកស្ថាបនាសង្គមទេ។ ផ្ទុយទៅវិញបើពន្ធពុំអាចគេចបាន ការ ផ្លាស់ប្តូរថ្លៃដែលទាក់ទងនឹងពន្ធ អាចបង្កើនការលើកទឹកចិត្តដើម្បីបែងចែកធនធានសាជាថ្មី។

## ១៦.ចូររៀបរាប់ដោយសង្ខេបអំពីស្ថានភាពចំណូលពន្ធនៅកម្ពុជា?

ចំ. កម្ពុជាមានអត្រាចំណូលពន្ធធៀបនឹងផលិតផលក្នុងស្រុកសរុបទាបជាង នៅប្រទេសដទៃទៀតនៅលើ ពិភពលោកគឺប្រមាណ ៨.៤ភាគរយនៃផ.ស.សនៅឆ្នាំ១៩៩៦ និង៨.៦ភាគរយនៃផ.ស.សនៅឆ្នាំ២០០០។ កាលនោះជាង៨០%នៃ ប្រាក់ចំណូលពន្ធសរុបបានមកពីពន្ធនាំចូល ប៉ុន្តែតួរលេខនៅក្នុងកំឡុង ឆ្នាំ២០១០ បានបង្ហាញថាប្រាក់ចំណូលពន្ធក្នុងស្រុកសរុប(ពន្ធដារ)មានចំណាយធំជាងវិញ។

អគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជា អនុវត្តការយកពន្ធតាមរបបស្វ័យប្រកាស និងរបបម៉ៅការ។ របប ស្វ័យប្រកាសអនុវត្តទៅលើសហគ្រាសធំ និងមធ្យម ហើយមានចំណែកជាង៨០% នៃចំណូលពន្ធសរុប ខណៈពេលដែលចំណូលពន្ធដាររបបម៉ៅការ

ដែលអនុវត្តទៅលើសហគ្រាសធំតូចមានចំណែកតិចជាង២០ ភាគរយនៃចំណូលពន្ធសរុប។ ហេតុនេះរដ្ឋត្រូវអនុវត្តកំណែទំរង់ពន្ធឱ្យមានប្រសិទ្ធភាព ពិសេសត្រូវឱ្យ មានចំណូលពន្ធកើនឡើងប្រមាណ១%ជារៀងរាល់ឆ្នាំ។

**១៧.តើអគ្គនាយកដ្ឋានពន្ធដារមានបេសសកម្មអ្វីខ្លះ?**

ចំ.អគ្គនាយកដ្ឋានមានបេសសកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទបញ្ញត្តនានាស្តីពីពន្ធដារដូចជា:

-ផ្តល់សេវាអ្នកជាប់ពន្ធរួមមានការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ

- អនុវត្តកម្មវិធីចាប់បង្ខំដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទ័ណ្ឌ តាមការអនុវត្តនៃច្បាប់ពន្ធដារចំពោះអ្នកជាប់ពន្ធដែលមិនបានប្រព្រឹត្តត្រឹមត្រូវតាមច្បាប់

- ប្រមូលចំណូលពន្ធ និងបង់ប្រាក់ពន្ធចូលថវិកាជាតិតាមការកំណត់នៃច្បាប់

- ផ្តល់សេវា និងអប់រំអ្នកជាប់ពន្ធ ដើម្បីធានាថាច្បាប់ស្តីពីពន្ធដារត្រូវបានអនុវត្ត និងគោរពត្រឹមត្រូវដ

- អនុវត្តកម្មវិធីចាប់បង្ខំឱ្យមានការទទួលខុសត្រូវ និងស្មើភាពចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់

- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្តចំពោះរដ្ឋបាល សារពើពន្ធ

- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនដើម្បីធ្វើ ឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ

- បង្កើនសមត្ថភាពចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ

- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធ ការងារដែលមានភាពច្បាស់លាស់ ទំនើប និងការទទួលខុសត្រូវខ្ពស់។

**១៨.តើអគ្គនាយកដ្ឋានពន្ធដារមានភារៈកិច្ចអ្វីខ្លះ?**

ចំ. ភារៈកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារមានដូចតទៅ:

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិការដ្ឋ

- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាននានាស្តីពីពន្ធដារកំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិត យុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់ថរក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ។

- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្តុំព័ត៌មាន។

- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ

- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ

- ទទួលបន្ទុកសហប្រតិបត្តការណ៍អន្តរជាតិក្នុងផ្នែកពន្ធដារ

- អនុវត្តទោសទ័ណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុកដែលល្មើសច្បាប់ពន្ធដា

- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ១៩.តើមានមធ្យោបាយអ្វីខ្លះ ដើម្បីពង្រឹងសមត្ថមានបច្ចេកទេសរបស់អគ្គនាយកដ្ឋានពន្ធដារ?

ចំ. មធ្យោបាយដើម្បីពង្រឹងសមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធដាររួមមាន:

- ពង្រឹងសមត្ថភាពមន្ត្រីពន្ធដារឱ្យមានចំណេះ និងជំនាញទាក់ទងទៅនឹងទស្សនៈទានពន្ធដារ គោល-នយោបាយពន្ធដារ ទំនាក់ទំនងរវាងពន្ធ និងអថេរម៉ាក្រូសេដ្ឋកិច្ចនានា ព្រមទាំងគោលការណ៍ សន្ធិសញ្ញា និងបញ្ហាពន្ធនៅលើពិភពលោក ។
- អភិវឌ្ឍន៏សមត្ថភាពស្ថាប័នក្នុងការវិភាគ និងប៉ាន់ប្រមាណចំណូល ព្យាករណ៍ និងបង្កើតគោលនយោ បាយពន្ធ ។
- បង្កើតប្រភពព័តិមាន និងផ្តល់ព័តិមានអំពីប្រព័ន្ធពន្ធ ។

## ២០.តើមន្ត្រីសវនកម្មពន្ធដារត្រូវធ្វើដូចម្តេចដើម្បីជួយបង្កើនប្រាក់ចំណូលពន្ធ?

ចំ. បច្ចុប្បន្នមានភស្តុតាងជាច្រើនបង្ហាញថា មានសហគ្រាសជាច្រើនបានប្រកាសថា ត្រូវមានការវាយ តម្លៃឡើងវិញនូវអគ្គនាយកដ្ឋានពន្ធដារ ចំពោះការប្រមូលចំណូល-ចំណាយរបស់សហគ្រាស ។ ប្រការនេះ
បានធ្វើឱ្យរដ្ឋបាត់បង់ចំណូលពន្ធមួយចំណែកធំ ។ ប្រការនេះទាមទារឱ្យមានការពង្រឹងការអនុវត្តច្បាប់ ពិសេសការងាររបស់មន្ត្រីសវនកម្មពន្ធដារដែលមានតួនាទីត្រួតពិនិត្យ និងវាយតម្លៃលើការប្រកាសចំនូល ចំណាយ ហើយជំរុញឱ្យមានការហូតពន្ធ និងការដាក់ពិន័យចំពោះសហគ្រាសដែលបានប្រព្រឹត្តផ្ទុយទៅនឹង ច្បាប់ស្តីពីសារពើពន្ធ និងច្បាប់ពាក់ព័ន្ធដទៃទៀត ។

មន្ត្រីសវនកម្មពន្ធដារគួរមានផែនការ សវនកម្មតាមសហគ្រាស វិធីសាស្ត្រក្នុងការជ្រើសរើសអ្នកជាប់ ពន្ធដែលត្រូវធ្វើសវនកម្មពន្ធដារ និងបច្ចេកទេសជាក់លាក់នានា ដើម្បីពិនិត្យមើលលើទិន្នន័យ ធ្វើការស្រាវជ្រាវ និងវិភាគ ធ្វើផែនការផ្ទៀងផ្ទាត់ និងគ្រប់គ្រងហានិភ័យ ។ ជាមួយនេះ មន្ត្រីសវនកម្មពន្ធដារ ត្រូវប្រកាន់ខ្ជាប់នូវការអនុវត្តច្បាប់សារពើពន្ធ និងច្បាប់ពាក់ព័ន្ធនានា ហើយពង្រឹងសមត្ថភាពរបស់ខ្លួន បន្ថែមទៀតចំពោះការត្រួតពិនិត្យ និងវាយតម្លៃទៅលើការប្រកាសចំណូលចំណាយរបស់សហគ្រាស ។

## ២១. ចូររៀបរាប់ប្រភេទឈ្មោះពន្ធដាឱ្យបានយ៉ាងតិចដប់?

ចំ.ពន្ធមានច្រើនប្រភេទដូចជា:ពន្ធលើប្រាក់បៀវត្សន៍ពន្ធលើប្រាក់ចំណេញពន្ធអប្បបរមាពន្ធកាត់ទុកអាករពិសេសអាករលើតម្លៃបន្ថែម អាករលើផលរបរ អាករបំភ្លឺសាធារណៈ ពន្ធប៉ាតង់ ពន្ធលើដីធ្លីមិន ប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធលើកេរមរតក ។ល ។

## ២២.តើក្រុមប្រឹក្សាឃុំ-សង្កាត់បានថវិកាមកពីណា ដើម្បីធ្វើការអភិវឌ្ឍន៍ឃុំ-សង្កាត់របស់ខ្លួន?

ចំ. - ឃុំ-សង្កាត់មានធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន

- ឃុំ-សង្កាត់មានសិទ្ធិទទួលចំណូលដោយផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធចំណូលសារពើពន្ធនិងចំណាយកម្រៃផ្សេងៗ ។ ពន្ធនេះរាប់បញ្ចូលពន្ធដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធដីការជួល ។

- ក្នុងករណីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ-សង្កាត់ ការប្រមូលចំណូលនេះ ត្រូវធ្វើក្នុងនាមឃុំ-សង្កាត់ ។

-ប្រភេទកិរិតនិងរបៀបរបបនៃការប្រមូលសារពើពន្ធចំណូលមិនមែនសារពើពន្ធនិងកម្រៃសេវាផ្សេងៗខាងលើនេះត្រូវកំណត់ដោយច្បាប់ ។ ម្យ៉ាងទៀតឃុំ-សង្កាត់មានសិទ្ធិទទួលនូវធនធានវិភាជន៍ពី ចំណូលរដ្ឋសម្រាប់ថវិការបស់ខ្លួន ។

## ១. ដូចម្តេចដែលហៅថាសេដ្ឋកិច្ច?

ចំ. សេដ្ឋគឺជាសំណុំនៃទំនាក់ទំនងផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែងធនធានក្នុង សង្គម។ ពាក្យនេះអាចជាកំណត់អំពីអត្តសញ្ញាណវិស័យ និងវាស់ទំហំសេដ្ឋកិច្ចមួយ។

ឧទាហរណ៍: សេដ្ឋកិច្ចឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្ម សេដ្ឋកិច្ចជនបទ។ តែបើយើងនិយាយអំពីសេដ្ឋកិច្ច- ជាតិ សេដ្ឋកិច្ចតំបន់ និងពិភពលោកគឺសេដ្ឋកិច្ចជាតិ < សេដ្ឋកិច្ចតំបន់ < សេដ្ឋកិច្ចពិភពលោក។

សេដ្ឋកិច្ចគឺជាកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រ ឧទាហរណ៍ វិទ្យាសាស្ត្រសេដ្ឋកិច្ច សេដ្ឋកិច្ចនយោបាយ ដែលនៅទីនេះសេដ្ឋចង់បញ្ជាក់អំពីកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រដែលសិក្សាពីទំនាក់ទំនង ក្នុងសង្គម។ ឬសេដ្ឋគឺជាការសិក្សាពីជម្រើសនៃការបែងចែកធនធានដែលមានដោយកម្រឱ្យមានប្រសិទ្ធិភាព ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្ស។ ធនធានសេដ្ឋកិច្ចមាន: ធនធានមនុស្ស (ពលកម្ម) ធម្មជាតិ(ដី រ៉ែ ទឹក...) មូលធន (លុយ) និងសហគ្រិនភាព (ទេពកោសល្យ ជំនាញ ជាន់ខ្ពស់)។

## ២. តើប្រទេសកម្ពុជាមានប្រព័ន្ធសេដ្ឋកិច្ច?

ចំ. ប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ជាផ្លូវការតាំងពីឆ្នាំ១៩៩៣ ដូចមានចែងក្នុងរដ្ឋ ធម្មនុញ្ញឆ្នាំ១៩៩៣។ កម្ពុជាបានបើកឱ្យមានកម្មសិទ្ធឯកជន និងធ្វើឯកជនភាវូបនីយកម្ម(បង្វែរអ្វីៗរបស់ រដ្ឋជារបស់ឯកជន) សហគ្រាសជាច្រើនឱ្យឯកជនកាន់កាប់វិញ។ ទន្ទឹមគ្នានោះ រដ្ឋអនុញ្ញាតឱ្យមានការធ្វើ ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស និងការវិនិយោគទុនក្រៅប្រទេសផងដែរ។សេដ្ឋកិច្ចទីផ្សារសេរីមានន័យ ថាកម្មសិទ្ធលើធនធានសេដ្ឋកិច្ចមួយភាគធំ ដែលស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជន ដែលជា នីតិបុគ្គល និងរូបវន្តបុគ្គល។ ដោយឡែកយន្ត ការគ្រប់គ្រង និងសម្របសម្រួលផ្នែកទាំងស្រុងលើយន្តការ ទីផ្សារដែលតាមទ្រឹស្តី Classic ហៅវាជាសេដ្ឋកិច្ចដែលធ្វើនិយ័តកម្មដោយខ្លួនឯង។ ក្នុងប្រព័ន្ធសេដ្ឋកិច្ច នេះសេដ្ឋកិច្ចសម្រេចចិត្តក្នុង ការបែងចែកធនធានជាសេរីភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗ។ សេរីភាព នេះអាស្រ័យលើតំរូវការ និងការផ្គត់ផ្គង់។ មានន័យថាសកម្មភាពផលិកម្ម ការដោះដូរ និងការប្រើប្រាស់ទំនិញ និងសេវាជាទូទៅត្រូវមានសេរីភាពបរិបូរណ៍។ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារសេរី ភ្នាក់ងារសេដ្ឋ-កិច្ចនីមួយៗគ្រប់គ្រងដោយខ្លួនឯងនូវអត្ថប្រយោជន៍ ផ្ទាល់ខ្លួននិងប្រឹងប្រែង ធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ ខ្លួនកាន់តែប្រសើរតាមរយៈការប្រកួតប្រជែង។

និយាយរួមសមាសភាគយន្តការមាន៥គឺ: កម្មសិទ្ធឯកជន សេរីភាពក្នុងការជ្រើសរើសអត្ថប្រយោជន៍ បុគ្គល ការប្រកួតប្រជែង និងប្រព័ន្ធបង្កើតថ្លៃ។

## ៣.ដូចម្តេចហៅថាហិរញ្ញវត្ថុសាធារណះ?

ចំ. ជាសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋ ក្នុងដំណើរការគៀងគររកចំណូល និងការទូទាត់លើ ចំណាយរបស់ខ្លួន។ ពោលគឺលើកកំពស់ប្រសិទ្ធិភាពចំនូលចំណាយហើយចំនាយ ប្រកបដោយវាចារណកម្ម រួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន មានការវិវឌ្ឍន៍ប្រកបដោយចិរភាព និងសមធមិដោយមាន ផលប៉ះពាល់តិចតួច លើសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ សកម្មភាព និងវិធាន ការហិរញ្ញវត្ថុសាធារណៈ ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធ និងពន្ធអាករការគ្រប់គ្រងចំនូលចំណាយ សាធារណៈ ការរៀបចំប្រាក់បៀវត្សន៍ សម្រាប់មន្ត្រីរាជការ ការគ្រប់គ្រងរតនាគារ ការលទ្ធកម្ម ការគ្រប់ គ្រងកំចីក្នុង និងក្រៅប្រទេស ការធានារ៉ាប់រង ការសន្សំក្នុងស្រុក ការរៀបចំមូលនិធិចូលនិវត្សន៍ និងការ លើកទឹកចិត្តវិនិយោគទុនជាដើម។

## ៤.ដូចម្តេចដែលហៅថាគោលនយោបាយសារពើពន្ធ?

ចំ.សំដៅលើការយកពន្ធនិងវិធីរកចំនូលផ្សេងៗទៀតរបស់រដ្ឋនិងចំណាយដោយបែងចែកធនធានសេដ្ឋកិច្ចក្នុងគោលបំណងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងសមធមិ។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធ រដ្ឋត្រូវអនុវត្តសកម្មភាពសំខាន់ដូចជា:

១.ប្រសិទ្ធភាពនៃការគ្រប់គ្រង និងគៀងគរចំនូល

២.ការធ្វើវិចារណកម្មចំណាយ គឺបែងចែកចំណាយថវិការដ្ឋរវាងការប្រើប្រាស់ និងការវិនិយោគសា-ធារណឱ្យបានសមស្រប។

គោលនយោបាយសារពើពន្ធរបស់ប្រទេសមួយ គួរមានគោលដៅជាគោលការណ៍ចំនួន៤គឺ:

- ការបែងចែកធនធាន

- ស្ថេរភាពវូបនីយកម្ម កិច្ចកំនើន និងការចែកចាយនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យបានស្មើរគ្នា។ តាមរយៈពន្ធ និងចំណាយសាធារណៈ រដ្ឋាភិបាលដើរតួនាទីសំខាន់ក្នុងការបែងចែកបណ្តាធនធាននៅក្នុង សេដ្ឋកិច្ច ជំរុញ និងមិនជំរុញ ខ្សែរសង្វាក់ផលិតកម្មឱ្យកើន ឬមិនកើនឡើង។ ពន្ធចំណាយសាធារណៈ និងសកម្ម និងសកម្មភាពទៀតរបស់រដ្ឋាភិបាលបន្ទាប់មក និងកំណត់សមាមាត្រផលិតផលជាតិសរុប ឬ ផលិតផលក្នុងស្រុកសរុបដែលបង្កើតឡើងដោយវិស័យសាធារណៈ។

## ៥.ដូចម្តេចដែលហៅថាថវិកាជាតិ?

ចំ. មានលក្ខណៈជាក់លាក់ពីព្រោះថវិកាត្រូវបានរដ្ឋសភាអនុម័ត ហើយឆ្លុះបញ្ចាំងកម្មវិធីនយោបាយរបស់ រដ្ឋ។ ថវិកាជាឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋ ឆ្លុះបញ្ចាំងសកម្មភាពសេដ្ឋកិច្ច ព្រោះថាថវិកាវិវឌ្ឍន៍ថ្នាក់ឡើង ចុះៗតាមសេដ្ឋកិច្ច ហើយក៏មានឥទ្ធិពលទៅលើសេដ្ឋកិច្ចវិញផងដែរ។ ដូច្នេះថវិកាមិនមែនត្រឹមតែជា-ឯកសារសម្រាប់កត់ត្រារបៀបគណនេយ្យនោះទេ។ ថវិកាបេសកម្មមួយច្បាស់លាស់គឺធ្វើវិចារណៈកម្មក្នុង ការអនុវត្ត និងការប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុដែលទទួលបាន បើចំណូលសារពើពន្ធចំណូលមិនមែន សារពើពន្ធ និងចំណូលមូលធន។ ថវិការដ្ឋាភិបាលគឺជាការប៉ាន់ស្មាននូវចំណូលនិងចំណាយរបស់រដ្ឋសរាប់ឆ្នាំបន្ទាប់ដែល ឧទិសភាពដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុនៅ ចំពោះមុខសភា ឬអង្គការនីតិបញ្ញត្តិ ដើម្បីសុំការអនុម័ត។

ថវិកាជាឧបករណ៍មួយដ៏ចាំបាច់សម្រាប់ឱ្យរដ្ឋដឹកនាំនយោបាយសេដ្ឋ និងហិរញ្ញវត្ថុបានត្រឹមត្រូវនិង ញុំាងឱ្យរដ្ឋក្តាប់ជាប់នូវការប្រព្រឹត្តទៅ និងអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនបានខ្ជាប់ខ្ជួន។ ថវិកាមាន តួនាទីមួយចំនួនដូចជា: តួនាទីផ្គត់ផ្គង់ធនធានដោយកំណត់តាមអាទិភាព តួនាទីបែងចែកដោយផ្ទេរធន-ធាន តាមមធ្យោបាយចំណូល និងចំណាយ និងតួនាទីស្ថេរភាពភាវូបនីយកម្មនៃម៉ាក្រូសេដ្ឋកិច្ចដែលរក្សា ឱ្យបានតុល្យភាពជាមូលដ្ឋានទាំងឡាយ។

## ៦.តើម៉ាក្រូសេដ្ឋកិច្ចជាអ្វី?

ចំ. ម៉ាក្រូសេដ្ឋកិច្ចគឺជាការសិក្សាទាំងមូលដែលពិនិត្យមើលអំពីផលិតកម្ម ភាពមានការងារធ្វើ( អនីកម្មភាព) ការប្រើប្រាស់ និងការវិនិយោគ កម្រិតថ្លៃជាទូទៅ"អតិផរណា" តម្រូវការ និងការផ្គត់ផ្គង់សរុប។

## ៨.តើមីក្រូសេដ្ឋកិច្ចជាអ្វី?

ចំ. មីក្រូសេដ្ឋកិច្ចគឺជាការសិក្សាអំពីឥរិយាបទ និងការធ្វើសេចក្តីសំរេចចិត្តរបស់បុគ្គលម្នាក់ៗ ក្រុមគ្រួសារ នីមួយៗ។

## ៩.តើការរៀបចំដំណើរការថវិកាជាតិធ្វើឡើងយ៉ាងដូចម្តេចខ្លះ?

ចំ. ដំណើរការរៀបចំថវិកាជាតិ:

- ខែ៣-៦: រំលឹកពិនិត្យថវិកា និងគោលនយោបាយអភិវឌ្ឍន៍ជាតិ
- ខែ៧-៩: ធ្វើផែនការពីក្រសួង ឬស្ថាប័ន
- ខែ១០-១២: អនុម័តក្នុងចំនោមក្រសួង-ស្ថាប័ន អនុម័តទៅគណៈរដ្ឋមន្ត្រី
- ខែ១២: អនុម័តទៅរដ្ឋសភា និងព្រឹទ្ធសភា។

## ១០ តើមីក្រូសេដ្ឋកិច្ច និង ម៉ាក្រូសេដ្ឋកិច្ចខុសគ្នាដូចម្តេច ?

ចំ. ភាពខុសគ្នារវាងមីក្រូសេដ្ឋកិច្ច និង ម៉ាក្រូសេដ្ឋកិច្ចខុស គឺអថេរដែលត្រូវសិក្សា។

មីក្រូសេដ្ឋកិច្ច សិក្សាថ្លៃដើមទាប( ថ្លៃអង្ករ ធៀបនឹងថ្លៃទំនិញផ្សេងទៀត) ចំណែក ម៉ាក្រូសេដ្ឋកិច្ច សិក្សាពីកំរិតថ្លៃមធ្យម ដែលគណនាដោយរាប់បញ្ចូលគ្រប់ទំនិញ និង សេវាប្រើទាំងអស់ ភាពខុសគ្នាមួយទៀតគឺការសន្មតិ។ ក្នុងការសិក្សាមីក្រូ សេដ្ឋកិច្ចគេឱ្យប្រាក់ចំណូលរបស់ខ្លួនដើម្បីទិញទំនិញផ្សេងៗ ចំនែកឯការសិក្សាមីក្រូសេដ្ឋកិច្ចវិញ កម្រិតនៃប្រាក់ចំណូលសរុប ឬ ចំនាយគឺស្ថិតនៅក្រោមអថេរសំខាន់ៗដែលត្រូវសិក្សា ក្រៅពីនេះមីក្រូសេដ្ឋ និងម៉ាក្រូសេដ្ឋកិច្ចសិក្សាអំពីទិដ្ឋភាពសេដ្ឋកិច្ចផ្សេងៗ គ្នា។ ការសិក្សាអំពីទីផ្សារទំនិញ ឬទីផ្សារពលកម្មតែមួយប្រភេទជាការសិក្សាក្នុងកម្រិតមីក្រូសេដ្ឋកិច្ច។

## ១១. តើប្រព័ន្ធសេដ្ឋកិច្ចមានប៉ុន្មាន? ចូររៀបរាប់ខ

ចំ. ប្រព័ន្ធសេដ្ឋកិច្ចមានបីគឺ: សេដ្ឋកិច្ចទីផ្សារសេរី សេដ្ឋកិច្ចបញ្ជារ ឬសេដ្ឋកិច្ចផែនការ និងសេដ្ឋកិច្ចចម្រុះ

-សេដ្ឋកិច្ចទីផ្សារសេរី: កម្មសិទ្ធលើធនធានសេដ្ឋកិច្ចមួយភាគធំ ស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជារូបវន្ត បុគ្គល និងនីតិបុគ្គល។ ដោយឡែកយន្តការគ្រប់គ្រង និងសម្របសម្រួលផ្នែកទាំងស្រុងលើយន្តការទីផ្សារដែលតាងទ្រឹស្តីក្លាស៊ិក ហៅថាជាសេដ្ឋកិច្ចដែលធ្វើនិយ័តកម្មដោយខ្លួនឯង។ ប្រព័ន្ធសេដ្ឋកិច្ចនេះ សេចក្តីសម្រេចចិត្តក្នុងការបែងចែកធនធានគឺជាសេរីភាព របស់ភ្នាក់ងារសេដ្ឋកិច្ច ជាការពិតសេរីភាពនេះអាស្រ័យទៅនឹងសេចក្តីត្រូវការ និងការផ្គត់ផ្គង់ក្នុងសង្គមសេដ្ឋកិច្ច។ ពីព្រោះមុន នឹងផលិតរបស់អ្វីមួយ ភ្នាក់ងារសេដ្ឋកិច្ចដែលជាផលិតករត្រូវសិក្សាសេចក្តីត្រូវការរបស់អតិថិជន ឬអ្នកប្រើប្រាស់។ ករណីនេះ សកម្មភាពផលិតកម្ម ការផ្លាស់ប្តូរ និងការប្រើប្រាស់ទំនិញ និងសេវាជាទូទៅត្រូវមានសេរីភាពបរិបូរណ៍។ ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច នេះ ភ្នាក់ងារសេដ្ឋនីមួយៗគ្រប់គ្រងដោយខ្លួនឯងនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងប្រឹងប្រែងធ្វើឱ្យសកម្មភាពអាជីវកម្មរបស់ខ្លួន កាន់តែប្រសើរឡើងតាមរយៈការប្រកួតប្រជែង។

-សេដ្ឋបញ្ជារៈរដ្ឋមានកម្មសិទ្ធិលើធនធាន និងកត្តាផលិតស្ទើរតែទាំងអស់ ឯយន្តការគ្រប់គ្រង និងសម្របសម្រួលផ្អែកលើមូល ដ្ឋានផែនការរបស់រដ្ឋ មានន័យថាដំណើរផលិតកម្មស្ថិតនៅក្រោមការការពាររបស់រដ្ឋស្ទើរតែទាំងអស់។ ដំណោះស្រាយធំៗទាក់ ទងទៅនឹងផលិតកម្ម ការគ្រប់គ្រង ការបែងចែកធនធានផ្សេងៗត្រូវស្ថិតនៅក្រោមការកំណត់របស់រដ្ឋ។ សហគ្រាសជាកម្មសិទ្ធិ របស់រដ្ឋដូច្នេះសកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចទាំងក្នុងផលិតកម្ម ការបែងចែកព្រមទាំងការផ្លាស់ប្តូរទំនិញ និងសេវាស្ថិតនៅ ក្រោមការត្រួតពិនិត្យនឹងត្រូវអនុវត្តតាមផែនការរបស់រដ្ឋ។

និយាយរួមផែនការផលិតកម្មរបស់សហគ្រាសនីមួយៗត្រូវចាត់ចែង និងត្រួតពិនិត្យ និងអនុវត្តតាមផែនការរបស់រដ្ឋដែលមាន ក្រុមប្រឹក្សាផែនការជាតំណាង ហើយជាទូទៅផែនការទាំងនេះជាអ្នកកំណត់ចំពោះសហគ្រាសនីមួយៗពីបរិមាណគុណភាព

បរិមាណគុណផល និងតើត្រូវផលិតអ្វី? ផលិតដូចម្តេច? សម្រាប់នរណា? ចំនួនប៉ុន្មាន? ក្នុងថ្លៃប៉ុន្មាន? ដូច្នេះសមាមាត្របរិមាណផលិតកម្មរវាងទំនិញវិនិយោគ និងទំនិញប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋត្រូវបានគ្រប់គ្រង និងកំណត់ដោយផែនការរដ្ឋ ។

-សេដ្ឋកិច្ចចម្រុះ៖យន្តការរដ្ឋ និងយន្តការទីផ្សារមានតួនាទីសំខាន់ៗដូចគ្នាក្នុងដំណោះស្រាយបញ្ហាថាផលិតអ្វី?ផលិតដូចម្តេច? ផលិតសម្រាប់នរណា?ក្នុងការអនុវត្តកន្លងមក ប្រព័ន្ធសេដ្ឋកិច្ចចម្រុះច្រើនស្ថិតនៅចន្លោះជាសេដ្ឋកិច្ចចម្រុះបែបទីផ្សារ ឬសេដ្ឋកិច្ចចម្រុះបែបសេដ្ឋកិច្ចបញ្ជារ ។ ឧទាហរណ៍ សេដ្ឋកិច្ចសហរដ្ឋអាមេរិកជាសេដ្ឋកិច្ចចម្រុះបែបទីផ្សារពីព្រោះថានៅក្នុងសកម្មភាពសេដ្ឋកិច្ចជាច្រើន ផ្នែកឯកជនដើរតួសំខាន់ ហើយសកម្មភាពមួយចំនួនទៀតដំណើរការដោយរដ្ឋខ្លួនឯង តាមរយៈការអនុវត្តបទបញ្ញត្តិផ្សេងៗ ការយកពន្ធ និងការឧបត្ថម្ភជាដើម ជាងនេះទៀតរដ្ឋមានតួនាទីសកម្មក្នុងការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមាននៅក្នុងដៃសម្រាប់សម្របសម្រួលក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចដូចជា គោលនយោបាយសារពើពន្ធសម្រាប់រក្សាស្ថេរភាពនៃការផ្គត់ផ្គង់ និងជម្រុញកំណើនសេដ្ឋកិច្ចព្រមទាំងផ្គង់ផ្គង់ទំនិញ និងសេវាសាធារណៈ ជាពិសេសទំនិញ និងសេវាដែលអវត្ត-មាននៅក្នុងទីផ្សារ ឬមានចំនួនតិច ។ តាមរយៈនេះការធ្វើអន្តរាគមន៍របស់រដ្ឋអាចកែសម្រួល និងបំពេញចន្លោះខ្វះខាតនូវយន្តការទីផ្សារ និងដើម្បីផ្ទេរសកម្មភាពទាំងនេះឱ្យក្លាយជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល ។

សេដ្ឋកិច្ចអតីតសហភាពសូវៀត និងបណ្តាប្រទេសនៅអឺរ៉ុបខាងកើតមានលក្ខណៈជាសេដ្ឋកិច្ចចម្រុះដែរ តែបែបសេដ្ឋកិច្ចផែនការ ។ ក្នុងករណីនេះពិតមែនតែអ្វីៗ(ទាំងកម្មសិទ្ធធនធានសេដ្ឋកិច្ច ការរៀបចំផែនការ ការអនុវត្តន៍ និងការត្រួតពិនិត្យ) ស្ថិតនៅក្នុងកណ្តាប់ដៃរបស់រដ្ឋ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង សេដ្ឋកិច្ចចម្រុះបែបបញ្ជារនេះជៀសមិនផុតពីការប្រើប្រាស់យន្តការទីផ្សារនោះទេពោលគឺនៅតែមានសេសសល់កម្មសិទ្ធឯកជនលើធនធានសេដ្ឋកិច្ចមួយចំនួន ។ បច្ចុប្បន្នកូរ៉េខាងជើង និងប្រទេសគុយបាអាចចត់ថាជាសេដ្ឋកិច្ចចម្រុះបែបបញ្ជារ ។

## ១៣. តើហិរញ្ញវត្ថុសាធារណៈជាអ្វី?

ចំ. ជាសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋក្នុងដំណើរការគៀងគររកចំនូល និងការទូទាត់លើចំណាយរបស់ខ្លួន ពោលគឺលើកកម្ពស់លើចំណូល-ចំណាយ ហើយចំណាយប្រកបដោយវិចារណកម្មរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន មានការវិវត្តប្រកបដោយចីរភាព និងសមធម៌ដែលមានផលប៉ះពាល់តិចតួចលើសកម្មភាពសេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ សកម្មភាព និងវិធានការនៃហិរញ្ញវត្ថុសាធារណៈរួមមានការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងពន្ធអាករដែលពួកក្រុមចំនូល-ចំនាយសាធារណៈ ការរៀបចំប្រាក់បៀវត្សន៍មន្ត្រីរាជការ ការគ្រប់គ្រងរតនាគារ ការគ្រប់គ្រងលទ្ធកម្ម ការគ្រប់គ្រងកម្ចីក្នុង-ក្រៅប្រទេសការធានារ៉ាប់រង ការសន្សំក្នុងស្រុក ការរៀបចំមូលនិធិចូលនិវត្ត និងការលើកទឹកចិត្តវិនិយោគទុនជាដើម ។

១៤. តើក្រសួងហិរញ្ញវត្ថុមានតួនាទីដូចម្តេចខ្លះ?

ចំ. មានតួនាទីគ្រប់គ្រងប្រាក់កម្ចី និងរក្សាទុនបម្រុងជារូបិយប័ណ្ណសម្រាប់ទប់ស្កាត់ឱនភាពថវិកាតាមរយៈការបង្កើនចំណូលសារពើពន្ធ និងមិនមែនសារពើ និងការកាត់បន្ថយចំណាយ ។

១៥. តើគោលនយោបាយពន្ធមានគោលបំណងអ្វីខ្លះ?

ចំ. ដើម្បីប្រមូលថវិកាសម្រាប់ទ្រទ្រង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការផ្តល់សេវាសាធារណៈចំពោះសង្គម ។ គោលបំណងផ្សេងទៀតគឺជម្រុញការបែងចែកឡើងវិញនូវរាល់ចំនូល និងកែតម្រូវអសុក្រឹតភាពទីផ្សារ ។

16.**ដូចម្តេចដែលហៅថាសេដ្ឋកិច្ច**?

ចំ.សេដ្ឋកិច្ចជាសំណុំនៃទំនាក់ទំនងផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការបែងចែកធនធានក្នុងសង្គម។ ពាក្យនេះអានជាការកំណត់សំគាល់អំពីអត្តសញ្ញាណវិស័យ និងវាស់ទំហំសេដ្ឋកិច្ចមួយ។ ឧទាហរណ៍ សេដ្ឋកិច្ចឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្ម សេដ្ឋកិច្ចជនបទ ។ តេបើយើងនិយាយអំពី សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ សេដ្ឋកិច្ចឧស្សាហកម្ម សេដ្ឋកិច្ចពិភពលោក។

សេដ្ឋកិច្ចជាកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រ **ឧទាហរណ៍៖** វិទ្យាសាស្ត្រសេដ្ឋកិច្ច សេដ្ឋកិច្ចនយោបាយ ដែលនៅទីនេះសេដ្ឋកិច្ចចង់បញ្ជាក់អំពីកម្មវត្ថុសិក្សា ឬជាវិទ្យាសាស្ត្រ ដែលសិក្សាពីទំនាក់ទំនងក្នុងសង្គម។ឬសេដ្ឋកិច្ចសិក្សាអំពីជម្រើសនៃការបែងចែកធនធានសេដ្ឋកិច្ចមានដូចជា៖ធនធានមនុស្ស(ពលកម្ម)ធម្មជាតិ(ដី រ៉ែ ទឹក.......)មូលធន(លុយ)និងសហគ្រិនភាព(ទេពកោសល្យ ជំនាញជាន់ខ្ពស់)។

17.**តើប្រទេសកម្ពុជាមានប្រពន្ធសេដ្ឋកិច្ចអ្វី**?

ចំ. ប្រទេសកម្ពុជាមានប្រពន្ធសេដ្ឋកិច្ចទីផ្សារសេរី ជាផ្លូវការតាំងពីឆ្នាំ១៩៩៣ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ កម្ពុជាបានបើកឱ្យមានកម្មសិទ្ធឯកជននិងធ្វើឯកជនភាវូបនីយកម្ម(បង្វែ របស់រដ្ឋជារបស់ឯកជន) សហគ្រាសជាច្រើនឱ្យឯកជនកាន់កាប់វិញ។ ទន្ទឹមគ្នានោះរដ្ឋអនុញ្ញាតឱ្យមានការធ្វើពាណិជ្ជកម្មក្នុង និងក្រៅប្រទេស និងការវិនិយោគទុនក្រៅប្រទេសផងដែរ។

សេដ្ឋកិច្ចទីផ្សារសេរីមានន័យថាកម្មសិទ្ធលើធនធានសេដ្ឋកិច្ចមួយភាគធំដែលស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជានីតិបុគ្គលនិងរូបវន្តបុគ្គល។ ដោយឡែកយនការគ្រប់គ្រង និងសម្រេមសម្រួលផ្នែកទាំងស្រុងលើយន្តការ ទីផ្សារដែលគ្មាទ្រឹស្តីជលាសសិច ហៅវាជា សេដ្ឋកិច្ចដែលធ្វើនិយកម្មដោយខ្លួនឯង។ ក្នុងប្រពន្ធសេដ្ឋកិច្ចនេះ សេដ្ឋកិច្ចសម្រេចចិត្តក្នុងការបែងចែកធនធានសេរីភាពរបស់ភ្នាក់ងារ សេដ្ឋកិច្ចនីមួយៗ។ សេរីភាពនេះអាស្រ័យលើតម្រូវការនិង ការផ្គត់ផ្គង់។ មានន័យថាសកម្មភាពផលិតកម្មការដោះដូរនិងការប្រើប្រាស់ទំនិញ និងសេវាកម្មជាទូទៅត្រូវមានសេរីភាពបរិបូរណ៍។ ក្នុងក្របខ័ណ្ឌ សេដ្ឋកិច្ចទីផ្សារសេរីភ្នាក់ងារសេដ្ឋកិច្ចនីមួយៗគ្រប់គ្រងដោយខ្លួនឯងនូវអត្ថប្រយោជន៍ផ្ទាល់ខ្លួន និងប្រឹងប្រែងធ្វើឱ្យស្ថានភាពអាជីវកម្មរបស់ខ្លួនកាន់តែប្រសើតាមរយៈការប្រកួតប្រជែង។

និយាយរួមសមាសភាគ យន្តការមាន៥គឺ៖ កម្មសិទ្ធឯកជន សេរីភាពក្នុងការជ្រើសរើស អត្ថប្រយោជន៍បុគ្គល ការប្រកួតប្រជែង និងប្រព័ន្ធបង្កើតថ្លៃ។

18.**ដូចម្តេចដែលហៅថាហិរញ្ញវត្ថុសាធារណៈ**?

ចំ.ជាសកម្មភាព និងមធ្យោបាយផ្សេងៗរបស់រដ្ឋ ក្នុងដំណើរការគៀងគរកចំណូល និងការទូទាត់លើចំណាយរបស់ខ្លួន។ ពោលគឺលើកកំពស់ប្រសិទ្ធិភាពចំណូលចំណាយហើយចំណាយប្រកបដោយវាចារណកម្ម រួមចំណែកធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន មានការរីវឌ្ឍន៍ប្រកបដោយចីរភាព និងសមធម៌ដោយមានផលប៉ះពាល់តិចតួច លើសកម្មភាពសេដ្ឋកិច្ចនិងជីវភាព រស់នៅរបស់ប្រជាពលរដ្ឋ។

សកម្មភាពនិងវិធានការហិរញ្ញវត្ថុសាធារណៈ ការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធ និងពន្ធអាករការគ្រប់គ្រងចំណូលចំណាយសាធារណៈការរៀបចំប្រាក់បៀវត្សន៍ សម្រប់មន្ត្រីរាជការ ការគ្រប់គ្រងរតនាគារ

ការលទ្ធកម្ម ការគ្រប់គ្រងកម្ចីក្នុងនិងក្រៅប្រទេស ការធានារ៉ាប់រង ការសន្សំក្នុងស្រុក ការរៀបចំមូលនិធិនូលនីវត្សន៍ និងការលើកទឹកចិត្តវិនិយោគទុនជាដើម។

19.**ដូចម្តេចដែលហៅថាគោលនយោបាយសារពើពន្ធ**?

ចំ.សំដៅលើការយកពន្ធ និងវិធីរកចំណូលផ្សេងៗទៀតរបស់រដ្ឋនិងចំនាយដោយបែងចែកធនធានសេដ្ឋកិច្ចក្នុងគោលបំណងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមធម៌។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធរដ្ឋត្រូវអនុវត្តសកម្មភាពសំខាន់ៗដូចជា៖

1. ប្រសិទ្ធភាពនៃការគ្រប់គ្រង និងគៀងគរចំណូល
2. ការធ្វើវិចារណកម្មចំណាយ គឺបែងចែកចំណាយថវិកាជួរវាងការប្រើប្រាស់ និងការវិនិយោគសាធារណឱ្យបានសមស្រប។

គោលនយោបាយសារពើពន្ធប្រទេសនីមួយ គួរមានគោលដៅជាគោលការណ៍ចំនួនបួនគឺ៖

- ការបែងចែកធនធាន
- ស្ថេរភាពភារូបនីយកម្ម កំណើន និងការចែកចាយនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យបានស្មើគ្នា។តាមរយៈពន្ធនិងចំណាយសាធារណៈរដ្ឋាភិបាលដើរតួនាទីសំខាន់ក្នុងការបែងចែកបណ្តាធនធាននៅក្នុងសេដ្ឋកិច្ចនិងជំរុញនិងមិនជំរុញខ្សែសង្វាក់ផលិតកម្មឱ្យកើន ឫមិនកើនឡើង។ ពន្ធចំណាយសាធារណៈនិងសកម្មនិងសកម្មភាពទៀតរបស់រដ្ឋាភិបាលបន្ទាប់មក និង កំណត់សមាមាត្រផលិតផលជាតិសរុប ឫផលិតផលក្នុងស្រុកសរុបដែលបង្កើតឡើងដោយវិស័យសាធារណៈ។

20.**ដូចម្តេចដែលហៅថាថវិកាជាតិ**?

ចំ.ដែលហៅថាថវិកាជាតិ មានលក្ខណៈជាក់លាក់ ពីព្រោះថវិកាត្រូវបានរដ្ឋសភាអនុម័តគ្រហើយឆ្លុះបញ្ចាំងកម្មវិធីនយោបាយរបស់រដ្ឋ។ ថវិកាជាឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋឆ្លុះបញ្ចាំងសកម្មភាពសេដ្ឋកិច្ចពីព្រោះថវិកាមិនត្រឹតែជាឯកសារសម្រាប់កត្រារបស់គណនេយ្យនោះទេ។ ថវិកាបេសកម្មមួយច្បាស់លាស់គឺធ្វើវិចារណៈកម្មក្នុងការអនុវត្តន៍ និងការប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុ ដែលទទួលបានពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងចំណូលមូលធន។ ថវិកាដ្ឋាភិបាលគឺជាការប៉ាន់ស្មាននូវចំណូល និងចំណាយរបស់រដ្ឋសម្រាប់ថ្នាក់បន្ទាប់ **ឧទ្ទេសភាព** ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុនៅចំមុខសភា ឫអង្គការនិតិបញ្ញត្តិដើម្បីសុំការអនុម័ត។

ថវិកាជាឧបករណ៍មួយដ៏ចាំបាច់សម្រាប់រដ្ឋដឹកនាំនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានត្រឹមត្រូវនិងញ៉ាំងឱ្យរដ្ឋក្តាប់ជាប់នៅការប្រព្រឹត្តទៅ និងអនុវត្តកម្មវិធីនយោបាយរបស់ខ្លួន បានខ្ជាប់ខ្លួន។ ថវិកាមានតួនាទីដូចខាងក្រោម៖

1. តួនាទីផ្គត់ផ្គង់ធនធាន ដោយកំណត់តាមអទិភាព
2. តួនាទីបែងចែកដោយផ្ទេរធនធានតាមមធ្យោបាយចំណូលនិងចំណាយ
3. តួនាទីស្ថានភាពភារូបនីយកម្មនៃម៉ាក្រូសេដ្ឋកិច្ចដែលរក្សាឱ្យបានតុល្យភាពជាមូលដ្ឋានទាំងឡាយ។

21. **ម៉ាក្រូសេដ្ឋកិច្ចជាអ្វី**?

ចំ. គឺជាការសិក្សាអំពីសេដ្ឋកិច្ចទាំងមូលដោយពិនិត្យមើលអំពីផលិតកម្មភាពមានការងារធ្វើ (អនីកម្មភាព)ការប្រើប្រាស់និងការវិនិយោគម្រិតថ្លៃជាទូទៅ(អតិផរណា)និងតម្រូវការនិងការផ្គត់ផ្គង់សរុប។

22. **មីក្រូសេដ្ឋកិច្ចជាអ្វី**?

ចំ. គឺជាការសិក្សាអំពីឥរិយាបទ និងការធ្វើសេចក្តីសម្រេចចិត្តរបស់បុគ្គលិកម្នាក់ៗ ក្រុមគ្រួសារនីមួយៗ និងក្រុមនិមួយៗ។

23. **តើរដ្ឋត្រូវធ្វើដូចម្តេចដើម្បីឱ្យពន្ធកើនឡើង**?

ចំ. បង្កើនអត្រាពន្ធ,ពង្រីមូលដ្ឋានយកពន្ធ (កន្លែងដែលមិនទាន់យក)

24. **ដំណើរការរៀបចំថវិកាជាតិមាន**

a. ខែទី៣ដល់ខែទី៦ ពិនិត្យថវិកា និគោលនយោបាយអន្តរជាឡើងវិញ
b. ខែទី៧ដល់ខែទី៩ ផែនការថវិកាពីក្រសួង ស្ថាប័ន
c. ខែទី១០ដល់ខែទី១២ អនុម័តក្នុងចំណោមក្រសួង ស្ថប័នអនុម័ត នៅគណៈរដ្ឋមន្ត្រី
d. ខែទី១២ អនុម័តនៅរដ្ឋសភា និងព្រឹទ្ធសភា

25. **ថវិកានិងហិរញ្ញវត្ថុសាធារណៈ**

- កម្មវិធីនយោបាយរបស់រដ្ឋាភិបាល
  - ចំណាយអន្តរជាតិមូលលធន
  - ចំណាយរដ្ឋបាល
    - ថវិកា
    - ចំណូល
      - ពន្ធ
      - មិនមែនពន្ធ
      - មូលធន
- ចំណាយ
- ថវិកាជំនួយ
- តុល្យភាព